**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**លេខ.........០៥២.........ដ.ន.ស**

ថ្ងៃពុធ ៤ រោច ខែពិសាខ ឆ្នាំវក ព.ស.២៥៦០

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែឧសភា គ.ស.២០១៦

# សារលិខិតជូនពរ

## សម្តេចអគ្គមហាពញាចក្រី ហេង សំរិន
## ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវ

សម្តេចអគ្គមហាពញាចក្រី និង លោកជំទាវ ជាទីគោរពដ៏ខ្ពង់ខ្ពស់ !

ក្នុងឱកាសដ៏មហានក្ខត្តឫក្ស នៃពិធីខួបកំណើតគម្រប់ ៨២ ឈានចូល ៨៣ ឆ្នាំ របស់សម្តេច ដែលនឹងចូលមកដល់នៅថ្ងៃពុធ ៤រោច ខែពិសាខ ឆ្នាំវក ព.ស.២៥៦០ ត្រូវនឹងថ្ងៃទី ២៥ ខែឧសភា គ.ស.២០១៦ យើងខ្ញុំទាំងអស់គ្នា ជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សូមបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ វត្ថុស័ក្តិសិទ្ធិក្នុងលោក ទេវតារក្សាព្រះរាជាណាចក្រកម្ពុជា ជាពិសេសទេវតាឆ្នាំថ្មី ព្រះនាម **មណ្ឌាទេវី** សូមប្រោះព្រំសព្ទសាធុការពរ បវរសួស្តី សិរីមង្គល វិបុលសុខ មហាប្រសើរ ជូន សម្តេចអគ្គមហាពញាចក្រី និង លោកជំទាវ ព្រមទាំងក្រុមគ្រួសារ សូមបានសម្រេចនូវពុទ្ធពរទាំង ៤ ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ និងសូមបានសម្រេចជោគជ័យយ៉ាងត្រចះត្រចង់ ក្នុងដំណើរការដឹកនាំប្រទេសកម្ពុជា ឆ្ពោះទៅកាន់សុខសន្តិភាព សម្បូណ៌រុងរឿង និងអភិវឌ្ឍន៍លើគ្រប់វិស័យជានិច្ចនិរន្តរ៍ ។

សូម សម្តេចអគ្គមហាពញាចក្រី ប្រធានរដ្ឋសភា និង លោកជំទាវ មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ និងស្មោះស្ម័គ្របំផុតពីយើងខ្ញុំទាំងអស់គ្នា ។

តំណាងថ្នាក់ដឹកនាំ

និងមន្ត្រីរាជការនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

**ជា សុផារ៉ា**